ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ០៦៤ ក.យ.ប្រក/២៣

# ប្រកាស
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្តុះបណ្តាលរបស់សិស្សចៅក្រមផ្នែកក្នុង

www.moj.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌

លេខ: ០៦៤ ក.យ.ប្រក/២៣

# ប្រកាស

## ស្ដីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្ដុះបណ្ដាលរបស់សិស្សចៅក្រមផ្ទៃក្នុង

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២៣/៥២០ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ១៧៩ កយ.ប្រក/២២ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ ស្ដីពីការធ្វើកម្មសិក្សារបស់សិស្សចៅក្រមផ្ទៃក្នុង
- យោងតាមតម្រូវការចាំបាច់ និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម



មហាវិថីសម្ដេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

# សម្រេច

**ប្រការ១ ..**

ប្រកាសនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្តុះបណ្តាលរបស់សិស្សចៅក្រមដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងផ្ទៃក្នុង តាមមាត្រា២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលតទៅនេះហៅថា "**សិស្សចៅក្រមផ្ទៃក្នុង**"។

**ប្រការ២ ..**

បន្ទាប់ពីទទួលបានជោគជ័យក្នុងការប្រឡងប្រជែង សិស្សចៅក្រមផ្ទៃក្នុងត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលត្រូវធ្វើឡើងនៅសាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

ការបណ្តុះបណ្តាលនេះ អាចត្រូវបានធ្វើឡើងដាច់ដោយឡែកពីគ្នា ឬរួមជាមួយគ្នានឹងការបណ្តុះបណ្តាលសិស្សចៅក្រម និងព្រះរាជអាជ្ញាដែលត្រូវបានជ្រើសរើសតាមមាត្រា១៩ និងមាត្រា៨២ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

**ប្រការ៣ ..**

សិស្សចៅក្រមផ្ទៃក្នុង ត្រូវទទួលការបណ្តុះបណ្តាល ដូចខាងក្រោម៖

- ការបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់សិក្ខាគារិកភាពដំបូង (ម៉ូឌុលទី១) សិក្ខាគារិកភាពជំនាញរួម (ម៉ូឌុលទី២) និងកម្មសិក្សារួម (ម៉ូឌុលទី៣) ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។
- ការបណ្តុះបណ្តាលមិនមែនជាកាតព្វកិច្ចសម្រាប់កម្មវិធីសិក្សាដែលជាបទបាឋកថា និងសិក្ខាសាលាផ្សេងៗ ដែលរៀបចំឡើងដោយបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីបណ្តុះបណ្តាលសិស្សចៅក្រម និងព្រះរាជអាជ្ញា។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចកែប្រែខ្លឹមសារ និងរយៈពេលនៃម៉ូឌុលនីមួយៗសម្រាប់ការបណ្តុះបណ្តាលជាកាតព្វកិច្ច ដោយយោងតាមតម្រូវការចាំបាច់ និងដោយផ្អែកតាមកម្មវិធីសិក្សារបស់បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

នៅពេលបញ្ចប់ការបណ្តុះបណ្តាលជាកាតព្វកិច្ច សិស្សចៅក្រមផ្ទៃក្នុងទាំងអស់ត្រូវឆ្លងកាត់ការប្រឡងបញ្ចប់ដែលត្រូវរៀបចំដោយបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។ ការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងបញ្ចប់ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមសំណើរបស់ប្រធានបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

**ប្រការ៤ ..**

សិស្សចៅក្រមផ្ទៃក្នុងទាំងអស់ដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យ ត្រូវទទួលបានសញ្ញាបត្រចេញដោយបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា និងត្រូវធ្វើកម្មសិក្សាដោយអនុលោមតាមប្រកាសលេខ ១៧៩ កយ.ប្រក/២២ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការធ្វើកម្មសិក្សារបស់សិស្សចៅក្រមផ្ទៃក្នុង។

**ប្រការ៥ .-**

សិស្សចៅក្រមផ្ទៃក្នុងជំនាន់ទី២ ដែលត្រូវបានតែងតាំងដោយប្រកាសលេខ ០៨០ កយ.ប្រក/២២ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ ហើយដែលទទួលបានការបណ្តុះបណ្តាលមុនប្រកាសនេះ ត្រូវចាត់ទុកថាបានទទួលការបណ្តុះបណ្តាលសម្រាប់ផ្នែក ឬកម្មវិធីដែលបានសិក្សារួច ស្របតាមម៉ូឌុលនីមួយៗដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

នាយកខុទ្ទកាល័យ ប្រធានបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា នាយកសាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៕

ថ្ងៃចន្ទ ៥រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ០៦៤ កយ.ប្រក/២៣ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្តុះបណ្តាលរបស់សិស្សចៅក្រមផ្នែកក្នុង

### ម៉ូឌុលទី១៖ សិក្ខាគារិកភាពដំបូង (រយៈពេល ១ខែ)

| ល.រ | មុខវិជ្ជា | ចំនួនម៉ោងសិក្សា |
|---|---|---|
| ១ | ពិធីប្រកាសបើកវគ្គបណ្តុះបណ្តាល និងពិធីសច្ចាប្រណិធាន | ៦ |
| ២ | បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌សិស្ស មន្ត្រីសុក្រឹតការ និងមន្ត្រីរិក្រឹតការ នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា | ៣ |
| ៣ | អំពីចៅក្រមនិងវិជ្ជាជីវៈច្បាប់ដទៃទៀត<br>- ទំនាក់ទំនងមុខងារចៅក្រមជាមួយនឹងវិជ្ជាជីវៈក្រឡាបញ្ជី<br>- ទំនាក់ទំនងមុខងារចៅក្រមជាមួយនឹងវិជ្ជាជីវៈអាជ្ញាសាលា<br>- ទំនាក់ទំនងមុខងារចៅក្រមជាមួយនឹងវិជ្ជាជីវៈមេធាវី<br>- ទំនាក់ទំនងមុខងារចៅក្រមអសនៈជាមួយនឹងវិជ្ជាជីវៈអយ្យការ<br>- ទំនាក់ទំនងមុខងារចៅក្រមអយ្យការ ចៅក្រមស៊ើបសួរ និងនគរបាលយុត្តិធម៌<br>- ទំនាក់ទំនងមុខងារចៅក្រមជាមួយនឹងសារការី | ១២ |
| ៤ | ក្រមសីលធម៌វិជ្ជាជីវៈចៅក្រម និងព្រះរាជអាជ្ញា | ៦ |
| ៥ | ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា | ៩ |
| ៦ | ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | ៦ |
| ៧ | ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ រួមទាំងរដ្ឋបាលសាលាជម្រះក្តី | ៩ |
| ៨ | វិធីសាស្ត្រគតិយុត្តទូទៅ<br>- លំហាត់អនុវត្ត<br>- វិភាគសាលក្រម និងអធិប្បាយសាលក្រម<br>- បរិមាធិប្បាយគតិយុត្ត | ៣៦ |
| ៩ | វិធីសាស្ត្រសំយោគអង្គហេតុ និងអង្គច្បាប់<br>- បច្ចេកទេសក្នុងការវិភាគអង្គហេតុ ការសរសេរសំអាងហេតុមុន និងការសំយោគអង្គច្បាប់នឹងការសម្រេចសេចក្តី<br>- វិភាគសាលក្រម សាលដីកា (ជាតិ និងអន្តរជាតិ)<br>- យុត្តិសាស្ត្រនៃតុលាការជាន់ខ្ពស់ | ១៥ |
| ១០ | ការគ្រប់គ្រងទិន្នន័យតាមព័ត៌មានវិទ្យា | ១២ |
| | **សរុប** | **១១៤** |

| | ទស្សនកិច្ចសិក្សា | ចំនួនម៉ោង |
|---|---|---|
| ១ | ប្រជុំណែនាំសិស្ស មុននឹងធ្វើទស្សនកិច្ចសិក្សា | ៣ |
| ២ | ទស្សនកិច្ចសិក្សានៅសាលាជម្រះក្តី (សាលាដំបូង និងតុលាការជាន់ខ្ពស់)<br>(ដើម្បីឱ្យសិស្សបានយល់អំពីលំហូរនៃការងាររដ្ឋបាល និងតួនាទីភារកិច្ចរបស់លេខាធិការដ្ឋាន និងអគ្គលេខាធិការដ្ឋានរបស់តុលាការ)<br>- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឬខេត្តកណ្តាល<br>- សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ<br>- តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល | ២៤ |

| | | |
|---|---|---|
| ៣ | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា<br>(បទបង្ហាញអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃ អ.វ.ត.ក.) | ៩ |
| ៤ | ទស្សនកិច្ចសិក្សាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | ៦ |
| ៥ | ប្រជុំបូកសរុប និងវាយតម្លៃ | ៣ |
| សរុប | | ៤២ |

## ម៉ូឌុលទី២៖ សិក្ខាគារិកភាពជំនាញរួម (រយៈពេល ៨ខែ)

### ក.ការសិក្សាស៊ីជម្រៅលើជំនាញផ្នែករដ្ឋប្បវេណី

#### ក.១ ការសិក្សាមុខវិជ្ជានីតិរដ្ឋប្បវេណី

| ល.រ | មុខវិជ្ជា | ចំនួនម៉ោងសិក្សា |
|---|---|---|
| ១ | គោលការណ៍ទូទៅនៃក្រមរដ្ឋប្បវេណី | ៩ |
| ២ | កិច្ចសន្យា និងគន្លឹះនៃការដោះស្រាយវិវាទកិច្ចសន្យា៖<br>- ការបង្កើត អានុភាព និងការបញ្ចប់កិច្ចសន្យា<br>- កិច្ចសន្យាលក់ ទិញ និងកិច្ចសន្យាសំខាន់ៗដទៃទៀត<br>- វិធីសាស្ត្រក្នុងការបកស្រាយកិច្ចសន្យា | ៤៥ |
| ៣ | ការលែងលះ និងគន្លឹះនៃការដោះស្រាយវិវាទលែងលះ៖<br>- អាពាហ៍ពិពាហ៍ និងអនីតិសង្វាស<br>- មូលហេតុនៃការលែងលះ<br>- ការបែងចែកទ្រព្យសម្បត្តិ<br>- ការកំណត់អ្នកមានអំណាចមេបា<br>- សិទ្ធិចូលជួបប្រាស្រ័យទាក់ទង និងអាហារកិច្ច | ២៤ |
| ៤ | ញាតិ និងទំនាក់ទំនងញាតិ៖<br>- សញ្ញាណនៃញាតិ ថ្នាក់ញាតិ បិតុភាព មាតុភាព និងបុត្តភាព<br>- ស្មុំកូនធម្មតា និងស្មុំកូនពេញលេញ<br>- ស្មុំកូនអន្តរប្រទេស<br>- ការកាត់កាល់ | ២១ |
| ៥ | សន្តតិកម្ម និងគន្លឹះនៃការដោះស្រាយវិវាទសន្តតិកម្ម៖<br>- ការបែងចែកមរតកតាមការព្រមព្រៀង និងតាមផ្លូវតុលាការ<br>- សន្តតិកម្មតាមច្បាប់ និងតាមបណ្តាំ<br>- ការផ្តាច់មរតក | ២១ |
| ៦ | អំពើអនីត្យានុកូល និងគន្លឹះក្នុងការស្វែងរកការទទួលខុសត្រូវក្នុងអំពើអនីត្យានុកូល៖<br>- សញ្ញាណនៃអំពើអនីត្យានុកូល<br>- មូលហេតុនៃការទទួលខុសត្រូវក្នុងអំពើអនីត្យានុកូល<br>- ការគណនាសំណងខូចខាត | ២១ |

| | | |
|---|---|---|
| ៧ | សិទ្ធិប្រត្យក្ស និងរបៀបនៃការដោះស្រាយវិវាទ៖<br>- សញ្ញាណនៃសិទ្ធិប្រត្យក្ស (កម្មសិទ្ធិ សិទ្ធិកាន់កាប់ សិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផល)<br>- សហកម្មសិទ្ធិ និងកម្មសិទ្ធិអវិភាគ<br>- របៀបនៃការដោះស្រាយវិវាទដីធ្លី<br>- គន្លឹះនៃការដោះស្រាយវិវាទអចលនទ្រព្យ | ២១ |
| ៨ | ការធានាកាតព្វកិច្ច និងគន្លឹះនៃការដោះស្រាយវិវាទទាក់ទងនឹងការធានាកាតព្វកិច្ច៖<br>- សញ្ញាណនៃការធានាកាតព្វកិច្ច<br>- សិទ្ធិប្រាតិភោគប្រត្យក្ស ជាអាទិ៍ (ហ៊ីប៉ូតែក ការបញ្ចាំ ប្រាតិភោគដោយអនុប្បទាន ឯកសិទ្ធិ សិទ្ធិឃាត់ទុក)<br>- កិច្ចសន្យាធានា | ២១ |
| ៩ | ការរលត់កាតព្វកិច្ច និងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល | ១៨ |
| **សរុប** | | **២០១** |

**ក.២ មុខវិជ្ជានីតិវិធីរដ្ឋប្បវេណី**

| **ល.រ** | **មុខវិជ្ជា** | **ចំនួនម៉ោងសិក្សា** |
|---|---|---|
| ១ | គោលការណ៍គ្រឹះនៃក្រមនីតិវិធីរដ្ឋប្បវេណី | ៩ |
| ២ | បណ្តឹង, ការពិនិត្យពាក្យបណ្តឹង (ទម្រង់នៃបណ្តឹង) និងការពិនិត្យអំពីលក្ខខណ្ឌនៃបណ្តឹង៖<br>- ទម្រង់<br>- អង្គហេតុ<br>- កម្មវត្ថុ<br>- សមត្ថភាពនៃការធ្វើបណ្តឹង<br>- សមត្ថកិច្ចរបស់តុលាការ<br>- ផលប្រយោជន៍នៃបណ្តឹង | ៤៥ |
| ៣ | នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល<br>- បច្ចេកទេសកំណត់ចំណុចវិវាទ<br>- ពិនិត្យលើករណីសិក្សាឱ្យបានច្រើន | ២៤ |
| ៤ | នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ | ១២ |
| ៥ | ការផ្អាក ការបង្អង់នីតិវិធីបណ្តឹង និងការបញ្ចប់នីតិវិធីដោយមិនធ្វើការសម្រេចសេចក្តី | ១៥ |
| ៦ | ភស្តុតាងក្នុងរឿងក្តីរដ្ឋប្បវេណី | ១៥ |
| ៧ | ការចាត់ចែងរក្សាការពារ | ២៤ |
| ៨ | នីតិវិធីការអនុវត្តដោយបង្ខំ៖<br>- នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យសងជាប្រាក់ និងការអនុវត្តសិទ្ធិប្រាតិភោគ<br>- នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលគ្មានគោលបំណងឱ្យសងជាប្រាក់<br>- ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ<br>- ស្ថាប័នអនុវត្ត | ៦៩ |

| | | |
|---|---|---|
| ៩ | បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ | ៩ |
| ១០ | ការជំនុំជម្រះសាជាថ្មី<br>- មូលហេតុនៅក្នុងមាត្រា៣០៧ មាត្រា៣១៥ មាត្រា៣១៦ និងមាត្រា៣១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី<br>- ការអនុវត្តជាក់ស្តែង<br>- ការអនុវត្តតាមនីតិវិធី | ១៥ |
| **សរុប** | | **២៣៧** |

## ខ. ការសិក្សាស៊ីជម្រៅលើជំនាញព្រហ្មទណ្ឌ

### ខ.១ ការសិក្សាមុខវិជ្ជាផ្នែកនីតិវិធីព្រហ្មទណ្ឌ

| ល.រ | មុខវិជ្ជា | ចំនួនម៉ោងសិក្សា |
|---|---|---|
| ១ | គោលការណ៍គ្រឹះនៃក្រមនីតិវិធីព្រហ្មទណ្ឌ<br>- តួអង្គសំខាន់ៗនៅក្នុងនីតិវិធីព្រហ្មទណ្ឌ<br>- គ្រឹះនៃការរៀបចំក្រមនីតិវិធីព្រហ្មទណ្ឌ<br>- នីតិវិធីបែបសរសេរ | ១២ |
| ២ | ការស៊ើបអង្កេត និងបច្ចេកទេសក្នុងការដឹកនាំការស៊ើបអង្កេត៖<br>- សញ្ញាណនគរបាលយុត្តិធម៌<br>- ការស៊ើបអង្កេតបឋម<br>- ការស៊ើបអង្កេតលើករណីជាក់ស្តែង<br>- របៀបនៃការដឹកនាំការស៊ើបអង្កេត( បឋម និងជាក់ស្តែង )<br>- ការគ្រប់គ្រងនិងថែរក្សាកន្លែងកើតហេតុ<br>- ការចាប់យកវត្ថុតាង | ២៤ |
| ៣ | ការទទួល ការពិនិត្យ និងការអនុវត្តបណ្តឹងអាជ្ញា<br>-បណ្តឹងទាមទារ និងបណ្តឹងបរិហារ<br>-គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់<br>(ការតម្កល់រឿងទុកឥតចាត់ការ និងការចោទប្រកាន់ ) | ២៤ |
| ៤ | ការស៊ើបសួររបស់ចៅក្រមស៊ើបសួរ<br>- ព្រំដែននៃការស៊ើបសួរ<br>ក.ព្រំដែនផ្នែកពេលវេលា (ពេលបើក និងបិទការស៊ើបសួរ)<br>ខ.ព្រំដែននៃសិទ្ធិអំណាចនៃការស៊ើបសួរ (អង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងគ្រប់បុគ្គលដែលពាក់ព័ន្ធនឹងអង្គហេតុ)<br>- សិទ្ធិអំណាចក្នុងការស៊ើបសួរ៖<br>ក.សិទ្ធិអំណាចក្នុងការស្រាវជ្រាវរកការពិត និងកាតព្វកិច្ចក្នុងការស៊ើបសួរ<br>ខ.សិទ្ធិអំណាចទាក់ទងនឹងការប្រើប្រាស់វិធានការនិរន្តរាយ ( ការរៀបរាប់ជាបញ្ជីនៃវិធានការនិរន្តរាយ ដែលបម្រើឱ្យការស៊ើបសួរស្វែងរកការពិត )<br>គ.ការបិទការស៊ើបសួរ ( ដីកាដំណោះស្រាយ )<br>ឃ.កិច្ចស៊ើបសួរនានារបស់ចៅក្រមស៊ើបសួរដែលអាចជាកម្មវត្ថុនៃការប្តឹង ( ការប្តឹងសុំមោឃកម្ម និងការប្តឹងឧទ្ធរណ៍ ) | ៣៦ |

| | | |
|---|---|---|
| ៥ | វិធានការនិរន្តរាយ | ១៥ |
| ៦ | ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ៖<br>- វិធាននៃភស្តុតាង<br>- របៀបវាយតម្លៃទៅលើប្រភេទនៃភស្តុតាង<br>- ប្រភេទនៃភស្តុតាង ការទទួលស្គាល់ និងការបដិសេធ<br>- ការគ្រប់គ្រង ថែរក្សា និងការចាត់ចែងវត្ថុតាង<br>- បច្ចេកទេសស្តាប់ចម្លើយ សាកសួរសាក្សី និងវិនិច្ឆ័យចម្លើយសាក្សី | ១៥ |
| ៧ | បច្ចេកទេសវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រសម្រាប់ពិនិត្យ និងវាយតម្លៃភស្តុតាង | ៩ |
| ៨ | យុត្តិធម៌អនីតិជន៖<br>- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>- នីតិវិធីកុមារមេត្រី<br>- នីតិវិធីបង្វែរ<br>- នីតិវិធីពាក់ព័ន្ធផ្សេងៗ | ៩ |
| ៩ | សវនាការព្រហ្មទណ្ឌ និងបច្ចេកទេសក្នុងការដឹកនាំសវនាការ<br>- ការរៀបចំដំណើរការសវនាការព្រហ្មទណ្ឌ<br>- ការដឹកនាំសវនាការព្រហ្មទណ្ឌ<br>- ការកោះហៅភាគីពាក់ព័ន្ធចូលក្នុងសវនាការ ក្នុងនីតិវិធីព្រហ្មទណ្ឌ | ១២ |
| ១០ | បណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងសើរើ | ៩ |
| ១១ | ការអនុវត្តសេចក្តីសម្រេចព្រហ្មទណ្ឌ (សាលក្រម សាលដីកា និងការបង្ខំដល់រូបកាយ) | ៩ |
| សរុប | | ១៧៤ |

### ខ.២ ការសិក្សាមុខវិជ្ជាផ្នែកព្រហ្មទណ្ឌទូទៅ

| ល.រ | មុខវិជ្ជា | ចំនួនម៉ោងសិក្សា |
|---|---|---|
| ១ | គោលការណ៍សំខាន់ៗនៅក្នុងក្រមព្រហ្មទណ្ឌ ពីមាត្រា១ ដល់មាត្រា២៣ ជាអាទិ៍៖<br>- គោលការណ៍នីត្យានុកូលភាព<br>- គោលការណ៍នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា<br>- គោលការណ៍នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហ | ១៥ |
| ២ | គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ៖<br>- បុគ្គលដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌ<br>- គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ<br>- គោលការណ៍ឯកត្តកម្មនៃទោស<br>- ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ និងការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ (ពីមាត្រា៣១ ដល់មាត្រា៣៧) | ១៥ |

| | | |
|---|---|---|
| ៣ | ទោស និងរបបនៃការប្រកាសទោស<br>- សញ្ញាណនៃទោសព្រហ្មទណ្ឌ<br>- ប្រភេទនៃទោសព្រហ្មទណ្ឌ(មូលទោស ទោសបន្ថែម ទោសជំនួស)<br>- ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស(ដែលមានចែងក្នុងច្បាប់ និងដែលជាឆន្ទានុសិទ្ធិរបស់ចៅក្រម)<br>- អាជ្ញាយុកាលនៃទោស<br>- អំពីគោលការណ៍ឯកត្តកម្មនៃទោស ស្ថានទម្ងន់និងស្ថានសម្រាលទោស ការអនុវត្តទោស និងការរំលត់ទោស | ៤៥ |
| សរុប | | ៧៥ |

**ខ.៣ ការសិក្សាមុខវិជ្ជាផ្នែកព្រហ្មទណ្ឌពិសេស**

| ល.រ | មុខវិជ្ជា | ចំនួនម៉ោងសិក្សា |
|---|---|---|
| ១ | សញ្ញាណនៃធាតុផ្សំបទល្មើសព្រហ្មទណ្ឌ | ៩ |
| ២ | បច្ចេកទេសក្នុងការវិភាគ និងកំណត់ធាតុផ្សំនៃបទល្មើសពិសេស<br>-បទល្មើសប្រឆាំងនឹងបុគ្គល(បច្ចេកទេសក្នុងការវិភាគបទល្មើសដែលកើតមានញឹកញាប់)<br>-បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ<br>-បទល្មើសប្រឆាំងនឹងរដ្ឋ<br>-បទល្មើសក្នុងច្បាប់ព្រហ្មទណ្ឌពិសេស (គ្រឿងញៀន សម្អាតប្រាក់ ជួញដូរមនុស្ស...) | ៦០ |
| | សរុប | ៦៩ |

**គ.រៀបសរសេរសាលក្រម និងសេចក្ដីសម្រេចផ្សេងទៀត**

**គ.១. រៀបសរសេរសាលក្រម និងសេចក្ដីសម្រេចរដ្ឋប្បវេណី**

| ល.រ | មុខវិជ្ជា | ចំនួនម៉ោងសិក្សា |
|---|---|---|
| ១ | ប្រភេទ និងទម្រង់នៃសេចក្ដីសម្រេចគោលការណ៍ទូទៅ<br>នៃការសរសេរសេចក្ដីសម្រេច ( ទាំងគោលការណ៍ ទាំងសញ្ញាណនៃការធ្វើសេចក្ដីសម្រេច) | ៩ |
| ២ | វិធីសាស្ត្រក្នុងការសរសេរសេចក្ដីសម្រេចរដ្ឋប្បវេណី៖<br>-ដីកាសម្រេច<br>-សាលក្រម<br>(អង្គហេតុ អង្គច្បាប់ ទំនាក់ទំនងរវាងអង្គហេតុនិងអង្គច្បាប់ និងការសម្រេចសេចក្ដី) | ៤៥ |
| | សរុប | ៥៤ |

**គ.២. រៀបសរសេរសេចក្ដីសម្រេចព្រហ្មទណ្ឌ**

| ល.រ | មុខវិជ្ជា | ចំនួនម៉ោងសិក្សា |
|---|---|---|
| ១ | ប្រភេទ និងទម្រង់នៃសេចក្ដីសម្រេចព្រហ្មទណ្ឌ<br>គោលការណ៍ទូទៅនៃការសរសេរសេចក្ដីសម្រេច<br>( ទាំងគោលការណ៍ ទាំងសញ្ញាណនៃការធ្វើសេចក្ដីសម្រេច) | ៩ |

| | | |
|---|---|---|
| ២ | វិធីសាស្ត្រក្នុងការសរសេរសេចក្ដីសម្រេច៖<br>-សេចក្ដីសម្រេចរបស់តំណាងអយ្យការ<br>-សេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ<br>-សេចក្ដីសម្រេចរបស់ចៅក្រមជំនុំជម្រះ | ៤៥ |
| | សរុប | ៥៤ |

**ឃ.សវនាការត្រាប់**

**ឃ.១. សវនាការត្រាប់រដ្ឋប្បវេណី**

| ល.រ | មុខវិជ្ជា | ចំនួនម៉ោងសិក្សា |
|---|---|---|
| ១ | ការណែនាំអំពីដំណើរការនៃសវនាការត្រាប់៖<br>-ការសិក្សាលើរឿងក្ដីគំរូ<br>-ការណែនាំអំពីនីតិវិធី (ដោយក្រុមគ្រូបង្គោល)<br>-ការបែងចែកតួនាទីក្នុងការធ្វើសវនាការត្រាប់<br>-ការសម្ដែង<br>-ការផ្ដល់មតិយោបល់របស់គ្រូដឹកនាំសវនាការត្រាប់ | ៣០ |

**ឃ.២.សវនាការត្រាប់ព្រហ្មទណ្ឌ**

| ល.រ | មុខវិជ្ជា | ចំនួនម៉ោងសិក្សា |
|---|---|---|
| ១ | ការណែនាំអំពីដំណើរការនៃសវនាការត្រាប់៖<br>- ការសិក្សាលើរឿងក្ដីគំរូ<br>- ការណែនាំអំពីនីតិវិធី (ដោយក្រុមគ្រូបង្គោល)<br>- ការបែងចែកតួនាទីក្នុងការធ្វើសវនាការត្រាប់<br>- ការសម្ដែង<br>- ការផ្ដល់មតិយោបល់របស់គ្រូដឹកនាំសវនាការត្រាប់ | ៣០ |

| **ទស្សនកិច្ចសិក្សា (ចល័ត)** | | |
|---|---|---|
| ១ | ប្រជុំណែនាំសិស្ស មុននឹងធ្វើទស្សនកិច្ចសិក្សា | ៣ |
| ២ | ទស្សនកិច្ចសិក្សានៅមណ្ឌលអប់រំកែប្រែ ម១ និង ម២ (ពន្ធនាគារព្រៃ ស) | ៦ |
| ៣ | ទស្សនកិច្ចសិក្សានៅស្ថាប័នអនុវត្តច្បាប់ (ដឹកនាំដោយព្រះរាជអាជ្ញា)<br>- អគ្គស្នងការដ្ឋាននគរបាលជាតិ<br>- អគ្គបញ្ជាការដ្ឋានកងរាជអាវុធហត្ថ<br>- ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់<br>- ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល | ៣០ |
| ៤ | ប្រជុំបូកសរុប និងវាយតម្លៃ | ៣ |
| | សរុប | ៤២ |

## ម៉ូឌុលទី៣៖ កម្មសិក្សារួម (រយៈពេល ៦ខែ)

| ល.រ | ការងារពាក់ព័ន្ធនឹងកម្មសិក្សា | ចំនួនម៉ោង |
|---|---|---|
| **កម្មសិក្សាផ្នែកអយ្យការ** | | |
| ១ | ការប្រជុំណែនាំសិស្ស មុននឹងចុះកម្មសិក្សា | ៣ |
| ២ | បទឧទ្ទេសនាមអំពីបច្ចេកទេសក្នុងការចុះកម្មសិក្សា និងការសរសេររបាយការណ៍ | ៣ |
| ៣ | កម្មសិក្សានៅស្ថាប័នអយ្យការអមសាលាដំបូង | ២៤០ |
| ៤ | ការការពាររបាយការណ៍កម្មសិក្សា | ៣០ |
| **សរុប** | | **២៧៦** |
| **កម្មសិក្សាផ្នែកតុលាការ** | | |
| ១ | ការប្រជុំណែនាំសិស្ស មុននឹងចុះកម្មសិក្សា | ៣ |
| ២ | បទឧទ្ទេសនាមអំពីបច្ចេកទេសក្នុងចុះកម្មសិក្សា និងសរសេររបាយការណ៍ | ៣ |
| ៣ | ការចុះកម្មសិក្សានៅតាមសាលាដំបូង | ៤៨០ |
| ៤ | ការការពាររបាយការណ៍កម្មសិក្សា | ៣០ |
| **សរុប** | | **៥១៦** |